**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង

យោងតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងពិធីសំណេះសំណាលជាមួយបងប្អូនកម្មករនិយោជិត កាលពីថ្ងៃទី៧ និងថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនអង្គការវិជ្ជាជីវៈ ជាពិសេសថ្នាក់ដឹកនាំសហជីពទាំងអស់ដែលកំពុងមានករណីបណ្តឹងនៅតុលាការ ឱ្យបានជ្រាបថា ដើម្បីសហការជាមួយក្រសួងយុត្តិធម៌ក្នុងការផ្តល់សេវាកម្មផ្នែកច្បាប់នៅក្នុងដំណើរការនីតិវិធីតុលាការ សំដៅឈានទៅដល់ការពន្លឿន និងបញ្ចប់សំណុំរឿងឱ្យបានឆាប់រហ័សស្របតាមបទប្បញ្ញត្តិជាធរមាន សូម អង្គការវិជ្ជាជីវៈ ជាពិសេសថ្នាក់ដឹកនាំសហជីពផ្តល់របាយការណ៍អំពីសំណុំរឿងរបស់ខ្លួនមកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ **ឱ្យបានមុនថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៨។**

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម អង្គការវិជ្ជាជីវៈ ជាពិសេសថ្នាក់ដឹកនាំសហជីពទាំងអស់ជ្រាបជាព័ត៌មាន និងសូមទំនាក់ទំនងមកក្រសួងតាមរយៈទូរសព្ទលេខ ០២៣ ៨៨១ ៩៤៣។

ថ្ងៃ ព្រហស្បតិ៍ ៧រោច ខែ កត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ២០១៨

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩